# ការសំភាសន៏របស់លោកពូនឹមមៀន

កះ អ្នកសំភាសន៍ដោយ  អ៊ុំប្រសិទ្ធ            ខះ អ្នកត្រូវបានគេសំភាសន៍លោកពូនឹមមៀន

## <u>ប្រវត្តរូបសង្ខេបរបស់លោកពូនឹមមៀន</u>

លោពូនឹមមៀនមានអាយុ៥៨ឆ្នាំ គាត់មានបងប្អូន៧អ្នក
គាត់មានទីរកន្លែងកំនើតនៅវត្តរម្ទូរស្រុកកំពង់សៀមខេត្តកំពង់ចាម
គាត់មកពីគ្រួរសាកសិករធ្វើស្រែចំការ គាត់បានកើតក្នុងអំឡុងឆ្នាំ១៩៦៥
គាត់មិនបានរៀនទេពីរមុនសមយ័ពុលពតនិង
គាត់មានជិវិតពិបាកមែនទែនក្នុងសមយ័ពុលពត
គាត់បានបាត់បងប្រុសគាត់ម្នាក់នៅក្នុងសមយ័ពុលពត
គាត់បានរៀនដល់ថ្នាក់ទីរប្រាំមួយក្រោយពីសមយ័ពុលពតបានបែកមក
ហើយបន្ទាប់មកគាត់ក៏បានធ្វើការជាទាហ៊ានហើយក៏បានរៀបការឆ្នាំ១៩៩៣ជាមួយភរយា
ឈ្មោះរស់ គន្ធា គាត់មានកូនប្រាំមួយអ្នក ហើយឥលូវគាត់គឺជាជាងធ្វើផ្ទះ លោកពូនឹម មៀន
គាត់បានផ្តាំផ្ញើសំរាប់មនុស្សជំនាន់ក្រោយអោយខំប្រឹងប្រែងរៀនសូត្រនិងក្លាយជាមនុស្សល្អ
នៅក្នុងសង្គម៕

កះ
អញ្ជឹងជាកិច្ចចាប់ផ្តើមតំបូងខ្ញុំសូមជំរាបសួរបងហើយខ្ញុំមកពីផ្នែកអង្គការមួយហើយសកលវិទ្យាលយ័ប៊ីបាយយូនៅសហរដ្ឋអាមេរិចអញ្ជឹងក្នុងអង្គការរបស់ខ្ញុំគេមានការស្រងើស្ថិតិអំពីវពង្សប្រវត្តមួយចំនួនដើម្បីទុកជាកេរមរតកដើម្បីជាសំរាប់មនុស្សជំនាន់ក្រោយសំរាប់បងមានចំនាប់អារម្មណ៍ឬក៏បងមានមារយល់ព្រមអោយពួកខ្ញុំធ្វើការសំភាសន៏បងទេយល់ព្រមអោយពួកខ្ញុំធ្វើការសំភាសន៏បងទេ?ខះ យល់ព្រមយល់ព្រម។ យល់ព្រមលោកពូ។

ខះ យល់ព្រម។

កះអញ្ជឹងលោកពូអញ្ជឹងខ្ញុំនឹងធ្វើការសំភាសន៍នៅថ្ងៃទីរ១១ថ្ងៃអាទិទ្យ២០១៨ហើយធ្វើការដោយខ្ញុំឈ្មោះអ៊ុំប្រសិទ្ធ។ហើយបងឈ្មោះពេញឈ្មោះអីគេដែលបង?

ខះ ឈ្មោះលីមមៀន។

ក៖លិមមៀន។

ខ៖នីមមៀន។

ក៖ នីមមៀន។

ខ៖បាទ។

ក៖បាទ។ក៖អញ្ចឹងពួកខ្ញុំនឹងធ្វើការសំភាសន៍ជាមួយបងឥលូវហ្នឹងតែម្តង។

ខ៖ បាទបាទ។

ក៖អញ្ចឹងឯអញ្ចឹងសំរសាប់បងឈ្មោះពេញឈ្មោះ?

ខ៖ នីមមៀន។

ក៖នីមមៀន។

ខ៖នីមមៀន។

ក៖មានឈ្មោះហៅក្រៅទេលលលោកពពូ?

ខ៖អត់ទេ។ក៖អត់ទេ។

ខ៖ និងហើយ។ក៖ហើយលោកពូមានអាយុប៉ុន្មានឆ្នាំហើយលោកពូ?

ខ៖ អាយុ៤៨។

ក៖ ៤៨។

ក៖បងមានបងប្អូនប៉ុន្មានអ្នកដែល?

ខ៖ បងប្អូន៦នាក់។

ក៖ ៧នាក់។

ខ៖ ហ្នឹងហើយ។

ក៖ បងជាកូនទីរប៉ុន្មានហើយ?

ខៈ បងជាកូនទីរ៣។

កៈ ជាកូនទីរ៣។

ខៈបាទ។

កៈបងស្គាល់ឈ្មោះបងប្អូនរបស់បងទាំងអស់ទេ?ខៈស្គាល់។កៈតាំងពីរកូនបងមកដល់កូន៧ណាបង។

ខៈ អ្នកងាប់អត់និយាយទេ?

កៈនិយយាយទាំងអ្នកដែលស្លាប់ដែល។

ខៈនឹមម៉ន់បងបង្អស់។

កៈបាទបង។

ខៈ ហើយបន្ទាប់មកបងស្រីឈ្មោះគិត, គូ,យ៉ូ,ណាន,ណុលហើយនិងនាគ។

កៈ បងមានទីរកន្លែងកំនើតនៅទីរណាដែល?

ខៈបងនៅវត្តរម្ងូរស្រុកកំពង់សៀមខេត្តកំពង់ចាម។

កៈខេត្តកំពង់ចាម។

កៈ ចុះបងមានចាំឈ្មោះម្តាយឪពុករបស់បងទេ?

ខៈចាំ។

កៈឈ្មោះអីគេដែលបង។

ខៈ ឈ្មោះនីមអាន។

កៈ សំរាប់ឈ្មោះឪពុកណាបង?

ខៈ គាត់ស្លាប់បាទ់ហើយ។ ខៈគាត់ស្លាប់បាត់ហើយ។

កៈម្តាយឈ្មោះអី?

ខះឈ្មោះអានឥលូវចាស់ចាស់ហើយ។

កះចាស់ហើយ សំរាប់ម្តាយគាត់មានព្រះជន្មប៉ុន្មានសំរាប់ម្តាយ?

ខះ សំរាប់ម្តាយគាត់មានអា៨០ជាង។

កះសំរាប់ឪពុកបងគាត់ស្លាប់នៅក្នុងជំនាន់ណាដែលបង?

ខះជនាន់៨៧។

កះជំនាន់៨៧។

ខះ បាទ។

កះ ហើយទីរកន្លែងកំនើតរបស់ពួកគាត់ទាំងពីរនៅ?

ខះនៅភូមិរម្ងូរនិង។កះនៅភូមិនិងដែលដូចគ្នា។ ខះ បាទដូចគ្នា។

កះ ខេត្តកំពង់ចាម។

ខះស្រុកកំពង់សៀម។

កះសំរាប់បងមានអំបាញ់មិុញបានរៀបរាប់អំពីបងប្អូនប្រុសនិងស្រីប៉ុន្មាននាក់ដែល?

ខះ ស្រី៣។

កះស្រី៣។

ខះ ស្រី៣ប្រុស៤។

កះ ស្រី៣ប្រុស៤អញ្ចឹង៧អ្នកហើយ?

ខះ បាទ៧នាក់។

កះ ហើយសំរាប់បងគឺកើតនៅស្រុរម្ងូរនិងតែម្តង?

ខះ បាទខ្ញុំកើតនៅស្រុករំម្ងូរនិងតែម្តងនៅឆ្នាំ៦៤។

កះ ៦៤។

កៈបងចាំពីរថ្ងៃខែឆ្នាំណាអត់?

ខៈ អត់ចាំទេ។

កៈចាំតែ៦៨និង។

ខៈ និងហើយ។

កៈ អញ្ចឹងសំរាប់ឆ្នាំខ្មែរវិញបងគិតនៅក្នុងឆ្នាំអីគេដែលបង?

ខៈ ឆ្នាំខ្ញុំទាល់ទៅមើលអត្តសញ្ញាណបណ័។

កៈ អត់អីបងមិនបាច់ហើយយើងគ្រាន់តែស្មានថាយើងកើតនៅខែមាឃ។

ខៈ ខែផ្គុណ។

កៈខែផ្គុណនិងបង។

ខៈ បាទនិងហើយ។

កៈហើយជាឆ្នាំបើបខ្មែរជាសត្វអីគេដែលបង?

ខៈ អើរ។

កៈខ្ញុំមមែលសំរាប់បងវិញ?

ខៈ ខ្ញុំឆ្នាំរការ។

កៈ អូរបង។

ខៈសត្វមាន់។

កៈបាទបង សំរាប់បងសមយ៏និងនៅពរលដែលបងដឹងក្តីមកគេហៅសមយ័អីគេដែលបង?

ខៈ សមយ័ជំនាន់ខ្មែរក្រហមនិង។

កៈជំនាន់ខ្មែរក្រហមម៉ងដឹងក្តី។

ខៈ បាទ។

ក៖ តែបងកើត៦៤ទេអី?

ខ៖៦៤។

ក៖៦៤វាអាចជាសម័យសម្ដេចឪ។

ខ៖ សម្ដេចឪ។

ក៖ សម័យសង្គមរាស្ត្រនិយម។

ខ៖ និងហើយតែយើងនៅតូចនិងណា។

ក៖យើងនៅតូច។

ខ៖ យើងនៅតូច។

ក៖ សំរាប់បង។

ខ៖ថ្ងៃគ្រាប់ផ្លោង។

ក៖សំរាប់បងបងមានទៅរៀននៅសាលាអីអត់?

ខ៖
នៅសាលាជូនណាតវត្តភ្នំរៀននៅថ្នាក់ទីប្រាំមួយ។ហើយរៀនថ្នាក់ទីប្រាំមួយហ្នឹងគេចាប់ធ្វើទាហ៊ាន។

ក៖ បាតបង។

ខ៖ធ្វើទាហ៊ាន។

ក៖អញ្ជឹងបងមានឧកាសរៀនក្នុងសម័យសង្គមរាស្ត្រនិយមនិងដែល?

ខ៖ អត់ទេពេដាច់អាពតហើយ។

ក៖អ្វីរដាច់។

ខ៖ដាច់៧៩ហើយ។

ក៖ដាច់៧៩ហើយ។

ខ៖ និងហើយ។

ក៖ អញ្ចឹងសំរាប់ជំនាន់១៩៦៩និងហើយមកដល់៧៣៧៩អីបងចាំពីរពេលវេលានិងទេ?

ខ៖ នៅចាំ៧៨ ៧៨និងធំហើយ។

ក៖ ៧៨អីចាំចាំ។

ខ៖ ចាំចាំរហូតមកដល់ឥលូវ។

ក៖
សំរាប់អញ្ចឹងសំរាប់បងមានអីគេខ្លះនៅក្នុងជិវិតនៅក្នុងសមយ័ពុលពតនិងបងអាចរៀបរាប់បាទទេ?

ខ៖ សមយ័ពុលពតបងនៅជាកុមានៅឡើយមើគោអីនឹង។

ក៖មើគោ។

ខ៖សំរាប់សុខភាពក្នុងសមយនិងបងមានអារម្មណ៍យ៉ាងម៉ិចដែល?
សំរាប់ជិវិតលំបាកស៊ីអត់ស៊ីឃ្លាននិងស៊ីវេទនាស៊ីក្លួចអីនិង។

ក៖ បាទ។

ខ៖ ដំឡូងអី។

ក៖បាទ។

ខ៖ ស៊ីត្រលាច។

ក៖បាទ។

ខ៖អត់មានឆ្អិតអីទេណា។

ក៖ បាទ។

ក៖
អញ្ចឹងខ្ញុំចងនិយាយតាំងពីរដើមមកវិញបន្តិចថាតើបងត្រូវគេជំលៀសទៅខាងណាដែលបង?

ខះទៅខាងល្អាងទៅស្រុកនៅស្រុកកំពង់សៀមនិងដដែលទេ។

កះនៅស្រុកកំពង់សៀមនិងទេអញ្ចឹងជំលៀស។

ខះជំលៀសនៅតាមមាត់ទន្លេ។

កះតាមមាត់តន្លេ។

ខះតាមមាត់ទន្លេ។

កះហើយនៅពេលដែលបងទៅជំលាសនិងជំលាសជាគ្រួសារឬក៏ទៅតែហាម្នាក់ឯង?

ខះទៅជាគ្រួសារ។

កះទៅជាគ្រួសារ។

កះសំរាប់ឪពុករបស់បងពីមុននិងសមយ័ពុលពតនិងគាត់ធ្វើអីគេដែលជាមួយនិងម្តាយនិង?

ខះខាងកសិកម្ម។

កះខាងកសិកម្ម។

ខះនេសាទអីនិងហើយយើងចេះអីទៅធ្វើខាងនិងទៅ។

កះបាទ។

ខះទៅជួនកាលទៅនេសាទត្រីអី។

កះបាទ។

កះបើឪពុកបងមានអាយុមកដល់ឥលូវគាត់មានអាយុប្រហែលប៉ុន្មានហើយបង?

ខះវាចូល៨៥ ,៨៨ហើយ។

កះ ៨៥,៨៨។

ខះគាត់កាល៨៧គាត់ស្លាប់និងគាត់អាយុ៦០។

កះ បាទគាត់កើតនៅឆ្នាំណាដែលមានចាំទេ?

ខ៖អត់ចាំទេ។

ក៖
អញ្ចឹងនៅពេលដែលគេជំលៀសក្រុមគ្រួសារបងទៅតើពួកគេតុកអោយពួកបងនៅជុំគ្នាឬក៏នៅបែកពីគ្នា?

ខ៖នៅបែកពីរគ្នា។

ក៖នៅបែកពីរគ្នា ហើយបងបងគាត់ាតទៅសហាករនោះទៅ។

ខ៖បងហ្មេះនៅអាកន្លែងរោងកុមារណោះទៅ។

ក៖ បាទនិងហើយ។

ខ៖មានតែបងនៅជាមួយម៉ាក់?

ខ៖ម្តាយនៅស្ទូងនៅឯរោងទៅហើយនៅផ្ទះទៅ។

ក៖បាទ។

ខ៖ អោយទៅស្ទូងដកស្ទូងដកអីទៅអត់អោយនៅផ្ទះ
ហើយយើងទៅមើលគោនៅឯកន្លែងកាលដ្ឋាននិងទៅ។

ក៖ ចុះភាគច្រើនការងាររបស់ម៉ាក់បងនៅសមយ័ពុលពតនិងគឺអត់សូវធ្វើអីទេ
អត់សូវធ្វើអីទេម៉ាក់បងចូលចិត្តធ្វើអីគេនៅសមយ័ពុលពតនិងឬក៏គេតំរូវអោយធ្វើអីគេដែល??

ខ៖ ធ្វើកសិករ។

ក៖ ធ្វើកសិករ។ ហើយឪពុកបងធ្វើកសិករដូចគ្នា?

ខ៖និងហើយធ្វើកសិករនិងនេសាទនិងឯង។

ក៖ បាទខាងនេសាទ។

ខ៖ហើយក៏បានមកជួបជុំកគ្នាដែល។

ក៖បងប្អូនរបស់បងស្លាប់នៅសមយ័ពុលពតនិងឬក៏?

ខះជំនាន់អាពតមួយ។

កះមួយដោយសារអីគេដែល?

ខះគេចោទថាលួចគោគេនិងឯង។

កះ និងលួចគោគេ។

ខះ ហើយទៅគេក៏ចាប់យកទៅវ៉ៃចោលនៅភ្នំប្រុសភ្នំស្រី។

កះ អូ៎រនៅភ្នំស្រីភ្នំប្រុសនិង។

ខះ និងហើយ។

កះ ហើយបងដែលលើកទំនប់អីអត់បង?

ខះ អត់ទេអត់ទេ។

ខះ នៅកុមារនៅឡើយ។

កះ នៅកុមារនៅឡើយ ហើយអត់ដែលបានក្លាជាឈ្លបអីអត់?

ខះ អត់ទេ។

កះ អត់ទេ។

ខះ នៅតូចដែល។

កះ នៅតូចដែល
បងនៅចចងចាំមនុស្សដែលគេអោយធ្វើការឈ្លបនិងហើយអាយុចាប់ពីអាយុប៉ុន្មានដែល?

ខះ អាយុជាង១០ឆ្នាំឡើងទៅ ១២ឬក៏១៥ឆ្នាំឡើងទៅ។

កះបាទដោយសាររូបភាពឯកសារខ្ញុំបានឃើញថាសុទ្ធតែក្មេងៗ។

ខះបាទសុទ្ធតែក្មេងៗចាប់ពីរ១០ឆ្នាំឡើងទៅដូចជា៧ឬក៏៨ឆ្នាំពួកវាយកទៅពង្វក់អីនិង។

កះបាទ។

កៈហើយសំរាប់ការហូបចុកវិញបងគិតយ៉ាងម៉ិចដែល?

ខៈ ហូបចុកវេទនាណាស់។

កៈ វេទនា។

ខៈមានតែបបរម៉ាកូនក្តាប់ទៅជូនកាលពេលខ្លះលួចលាយក្តួចហើយចេកនិងណា។

កៈបាទ។

ខៈ បានហុចទៅបានម៉ាចានម៉ាវែកពីរវែកទៅតំរង់ជួរគ្នាយកទៅ។

កៈតំរង់ជួរគ្នានិង។

ខៈៈ បើទៅមិនទាន់អត់ហើយនិង។

កៈ តើញាំជាគ្រួសារឬក៏ជាសហាករ?

ខៈជាសហាករ។

កៈជាសហាករម៉ង ពាក្រពេចអីគេខ្លះដែលបងចងចាំជាគេនៅពេលសមយ័ពុលពតនិង?

ខៈ នៅសមយ័ពុលពតនិង។

កៈ ដែលគេចូលចិត្តប្រើ។

ខៈ
គេចូលចិតត្តប្រើវែកដីអីនិងលើកទំនប់លើកបន្លាយវែកដីអីនិងគេអោយយើងសែងវែកដីអីនិង
។

កៈ ហើយសំរាប់ពាក្រដែលពុលពតចូលចិត្តប្រើជាងគេទៅដូចជាពាក្រសមមិត្តអីគេទៀត?

ខៈ និងហើយសមមិត្តនិងហើយអង្គការអីនិងហើយមិនត្រូវយកសំលាប់ចោលទៅ។

កៈបាទ។

ខៈ ខុសសិលធម័។

កៈ បាទ។

ខ៖ គេយកទៅហើយ។

ក៖ ខ្ញុំដូចជាធ្លាប់លឺគេនិយាយថាយកទៅកសាងអីលោកពូ។

ខ៖មុនគេយយយកទីកសាងសិនហើយមកសារក្រោយបើមិនតាមទេគេយកទៅសំលាប់ចោល។

ក៖ គេយកទៅសំលាប់ចោល។

ខ៖ បាទ។

ក៖
គេដែលនិយាយត្រង់ថាគេយកទៅសំលាប់ឬក៏គេនិយាយបង្វៀងយកទៅក៏សាងហើយរៀនសូត្រហើយក៏បាត់ខ្លួនតែម្ដ៉ង?

ខ៖ ពេលខ្លះវាភរយើងថាក៏សាងហើយយកយើងទៅតែម្ដង។

ក៖ យកទៅកសាង។

ខ៖
ហើយបើយើងអតើដឹងគេយកយើងទៅវ៉ៃសំលាប់ចោលនៅតាមរណ្ដៅព្រៃកប្រាំងអីចឹងទៅ។

ក៖ បាទលោកពូ
ដោយសារតែសំនុំរឿងក្ដីខ្មែរក្រហមយើងបច្ចុបន្ននិងថាគេងត់បានដឹងអំពីបញ្ហាទាំងអស់និងទេ។

ខ៖ បាទ។

ក៖ តែកាលសមយ័និង។

ខ៖ ទាន់តើ។

ក៖ អីគេអំពើលឃោឃៅទាំងលាយណាដែលបានមើលឃើញនិងភ្នែក?

ខ៖ វាជែកឃើញនិងភ្នែកវាអោយយើងជិះកង់ហើយវាអ្នកឌុប។

ក៖ បាទ។

ខ៖  គេចងស្លាបសេកពីរក្រោយហើយនិងណា។

ក៖ បាទ។

ខ៖ វាជិះចុះទូលហើយបន្ទាប់មកវាអោយយើងជិះពីរក្រោយ។

ក៖ បាទ។

ខ៖
ហើយដល់វាចុះទួរហើយវាពិសោធន៍ហើយមើលទៅចុះទូលហើយវាប្រលេងយើងទៅអញ្ចឹងយើងមានអីតោង។

ក៖ បាទ។

ខ៖ ចងស្លាបសេកហើយធ្លាក់ហុយដីស្ពឹង។

ក៖ បាទ។

ខ៖ មើលថាវាបានសប្បាយចិត្តហើយរួចទៅគឺវាយកយើងទៅវៃចងនៅក្នុងព្រៃ។

ក៖
ហើយអំពើលអាក្រក់អញ្ចឹងហើយហេតុអីបានពួកសាលុតសរដែលហៅកាត់ថាពុលពតនិងឬក៏ខែសំភេងអីគេបាននិយាយថាគេអត់បានដឹងរឿងទេ។

ខ៖ អត់ដឹងដឹងម៉ិចវាជាអ្នកធំនៅខាងលើ។

ក៖ បាទ។

ខ៖ នៅសល់តែពួកអាក្រោមៗ។

ក៖ ពួកអាក្រោមៗ។

ក៖ អញ្ចឹងមានអ្នកស្លាប់ជាង១លាន៨សែនដែលបានស្លាប់អញ្ចឹងវាច្រើនគួរសម្បដែល។

ខ៖ បាទ។

ក៖ អត់តិចទេ។

ខ៖  បាទអត់តិចទេ។

ក៖  បាទ។

ខ៖ ស្លាប់គ្រប់ស្រុកគ្រប់ភូមិ។

ក៖ បាទ។

ក៖ ដូចជាខ្ញុំបានសំភាសន៍អ្នកខ្លះគេថាគេនៅតំបន់ដែលស្រួលភូមិស្រួលតែម្ដង?

ខ៖  មានភូមិខ្លះ ភូមិគេស្រួល។

ក៖  បាទ។

ខ៖ មានបាយមានទឹកចឹងទៅ ភូមិខ្លះអត់ទេស៊ីតែបបរអីទេលាយជាមួយក្ដួច។

ក៖  បាទ។

ខ៖  ពេលខ្លះបាយលាយចេកមួយគ្រាប់ៗៗៗទៅ។

ក៖ បាទ។

ខ៖ បើអត់ចេះស៊ីដូចជាគេស្ដមដូចជាកុកចឹងទៅ រាកអាចន៍ចឹងទៅដេក។

ក៖ ជំនាន់នឹងមានលោកគ្រូពេទ្យអីគេទេ?

ខ៖  មាន  មានតែនៅពេលតាមសហករអីនិង។

ក៖ បាទ។

ខ៖ នៅតាមចលត័។

ក៖ បាទ។

ខ៖ អញ្ចឹងចាំមានគ្រូពេទ្យនៅតាមសហករអីនិង។

ក៖ នៅតាមសហករនិងទេ។

ក៖ ចុះពេទ្យមានគ្រឿងប្រដាប់ប្រដាអីល្អអីទេលោកពូ?

ខ៖ មានបងនៅកុមារចឹងបងអត់ស្ទូវទៅកន្លែងសហាករចឹងបងអត់ស្ទូវដឹងទេ។

ក៖ បាទ។

ខ៖ តែមានដឹងថានៅតាមសហាករមានពេទ្យដែល។

ក៖ មានពេទ្យដែលលោកពូ។

ក៖ ហើយ មានបងប្អូនបងឬក៏បងផ្ទាល់បានទៅចូលពេទ្យហ្នឹងអត់?

ខ៖ មានៗព្រោះអីគាត់ធំៗគាត់ដឹងអស់ហើយ។

ក៖ បាទ។

ខ៖ គាត់នៅខាងចលត័អីចឹងណា។

ក៖ បាទ។

ក៖ ក្នុងមួយឆ្នាំគេមានធ្វើកម្មវិធីឬក៏ជប់លាងកាញ្ញាំអីអោយបានបបូរអីម្តងអីអត់លោកពូ?

ខ៖ អត់ដែលទេ។

ក៖ អត់ដែលទេ។

ក៖៖ មានតែញ៉ាំជាសហាករបានតិចៗ។

ខ៖ មានតែញ៉ាំជាសហាករ។

ខ៖ ហ្នឹងហើយ។

ក៖ សំរាប់បង បងនៅចាំថានៅក្នុងខ្វះម៉ាខ្វះធំមានគេដាក់អង្ករប៉ុន្មានដែលបង?

ខ៖ អង្ករកន្លះកាប៉ុងចឹងទៅ។

ក៖ កន្លះកំប៉ុង។

ខ៖ សល់ម៉ានម៉ាកាប៉ុងឬក៏២កាប៉ុងចឹងទៅ។

ក៖ ចឹងក្នុងពេលបងនៅវយ័កុមារនិងបងៗរបស់បងដែលមានផ្តល់អីដល់អីញ៉ាំខ្លះ?

ខ៖ អត់ទេ។

ក៖ អត់ទេ។

ខ៖ បាទ។

ខ៖  ចាំដល់ម៉ោងគេវ៉ៃជួងចានមួយម្នាក់ទៅហើយ។

ក៖ ទៅហើយ។

ខ៖ បងដួសក្រោយគេចឹងរាប់វែក។

ក៖ បាទុ។

ខ៖ ដាក់ចាននិង។

ក៖ ចុះបងដែលមានដែលលួចគាស់ដំលូងអីអត់?

ខ៖ អត់ទេ។

ក៖ អត់ទេ។

ខ៖ ធ្លាប់បេះសណ្តែកអី។

ក៖ បេះសណ្តែក។

ខ៖ ស៊ីគេរត់ដេញចាប់ម្តុំង។

ក៖ គេ ធ្លាប់លឺគេនិយាយថាមានញាំស្លឹកឈើអីតើមានស្លឹងឈើប្រភេទអីខ្លះដែលអាចញាំបាន?

ខ៖ មានតែគល់ល្ហុង។

ក៖ គុល្ហុង។

ខ៖ និងហើយ ហើយអាត្រលាចយើងផ្លែត្រលាចផ្លែល្ហុងអីនិងផ្លែទ្រាប់នៅអីនិង។

ក៖ បាទ។

ខ៖ និងហើយ ជូនកាលអាតំលូងគេដាំអីនៅចំការអីនិង។

កៈ បាទ។

ខៈ ទៅលួចទៅដកស៊ីទៅដល់ទាំងមើមត្រដឹក។

កៈ បាទ។

ខៈ បែកពពុះមាត់។

កៈ សំរាប់កាលផឹកទឹកវិញទឹកដូចជាគេផឹកទឹកអីគេវិញលោកពូ?

ខៈ ទឹកតាមនេះនិង។

កៈ តាមព្រៃក។

ខៈ តាមព្រៃកតាមបឹង។

កៈ តាមទឹកបឹង។

ខៈ ហ្នឹងហើយ។

កៈ មានអីចម្រោះអីត្រឹមត្រូវអីអត់?

ខៈ អត់ទេ ជំនាន់នោះអត់មានទេ។

កៈ អត់មានទេ។

ខៈ ហើយដាក់ពាងដាក់ប៉ោតអី។

កៈ បាទ។

ខៈ សំរាប់ការធ្វើស្រែអីវិញបងមានដែលធ្វើស្រែអីអត់?

ខៈ អត់ អត់ដែល។

កៈ អត់ដែលទេលោកពូ។

ខៈ គ្រាន់តែបានជួយជញ្ជូនកណ្តាប់អីគេចឹងទៅ។

កៈ ភាគច្រើន។

ខ៖ នៅមើលគោអីទៅ។

ក៖ ក្រុមកសិករដឹងថាការប្រមូលផលស្រូវយកទៅណាអីអត់?

ខ៖ យកដាក់ទៅឃ្លាំង។

ក៖ យកដាក់ទៅឃ្លាំង។

ខ៖ ដាក់ទៅឃ្លាំង។

ក៖ តែប៉ុន្នឹង។

ខ៖ គេមានឃ្លាំង។

ក៖ ដឹងតែប៉ុន្នឹងអីទេលោកពូ?

ខ៖ មានតែប៉ុន្នឹងទេ។

ក៖ អត់ដឹងថាពុលពតគាត់យកទៅណាទេ?

ខ៖ មិនដឹងពួកវាយកទៅណាទៅនៃទេគ្រាន់តែដឹងថាដាក់ក្នុងឃ្លាំនិង។

ក៖
ហើយនៅក្នុងសមយ័និងបងគិតថាហេតុអីវាទៅដល់ឈានទៅដល់ការរស់នៅជាសហគមអីអត់ដោយសារភាគច្រើគេរស់នៅជាក្រុមគ្រួសារពេលរស់នៅជាសហគមចឹងទៅ?

ខ៖ អត់។

ក៖ មានអារមណ៍អីចំលែកអីទេ។

ខ៖
មានដែលដូចជាយើងនៅម៉ាពេងអីចឹងទៅចាស់ៗអីនិងដូចជាយាយៗនៅមើលចៅមើកូនអោយគេនិង។

ក៖ បាទ។

ខ៖ ម៉ែឪទៅស្ទូងដក អស់ហើយនៅតែយើងចាស់ៗនៅមើលកុមារៗ។

ក៖
ពេលវេលាដែលគេចូលធ្វើការតើនៅពេលព្រះអាទិទ្រវះហើយរហូតដល់ព្រះអាទិត្តលិចឬក៏ពីរពេលវេលាម៉ោងណា?

ខ៖ និងហើយ។

ក៖ និងហើយម៉ោងប្រាំបី?

ខ៖ ម៉ោងប្រាំមួយពេលព្រឹករហូតដល់ម៉ោងពេលបាយ។

ក៖ រហូតដល់ម៉ោងពេលបាយ។

ខ៖ និងហើយពេលបបរហើយដល់ពេលគេជួសជួងហើយក៏ឡើងមក។

ក៖ បាទ។

ខ៖ បានឡើងហូប ហូៗអីហូប បបរតាមនេះនិងតាមរោងបាយ។

ក៖ បាទ។

ខ៖ បាទនិងហើយ។

ក៖
អញ្ចឹងសំរាប់សហាគមបងតើមានក្មេងដែលជាក្មេងឆ្លាតដែលគេអោយនៅតែបន្តរៀនអីចឹងអីទេបង?

ខ៖ នៅជំនាន់និង?

ក៖ បាទ។

ខ៖ អត់មានទេ។

ក៖
ដោយសារនៅឆ្នាំ១៩៧០ដូចជា៧៨គឺមានជនជាតិបទេសម្នាក់បានមកដល់ប្រទេសខ្មែរដែលយើង?

ខ៖ នៅទេ។

កៈ ប៉ន្តែដោយសារ។

ខៈ ម៉ាជំនាន់និងនៅ បើថានៅភ្នំពេញប្រហែលមានណា។

កៈ បាទ

ខៈ ប៉ុន្តែនៅជនបទ។

កៈ អត់មានសាលាបង្រៀនអីនិង។

ខៈ បាទ។

កៈ ដោយសារគេបានមកប៉ុន្តែពុលពតបានលាក់បាំង

ខៈ បាបលាក់បាំង

កៈ កគេមកឃើញប្រជាជនរស់សំបូរសប្បាយធម្មតាអីទេនៅក្នុងក្រុងភ្នំពេញអីនិង។

ខៈ និងហើយ។

កៈ ប៉ុន្តែគេអត់ដឹងតាមពិតគេអត់ដឹងភាពខាងអោយស៊ីជំរៅគឺថាមានប្រជាជនវេទនាជាច្រើន។

ខៈ និងហើយវាមានប្រជាជនវេទនាជាច្រើនស៊ីក្តួចស៊ីអីផ្សេងៗពិបាកមែនទេន។

កៈ បាទ។

ខៈ លួចស៊ីបាយជ្រូកក៏មាន។

កៈ ហើយបងដែលចូលរួមក្នុងសកម្មភាពអាសកម្មភាពថាសកម្មភាពរៀបការជាក្រុមអី?

ខៈ អត់ទេ។

កៈ អត់ទេអត់ដែលឃើញអីទេ?។

ខៈ អទ់ទេ។

កៈ ស្ងម្បីតែឃើញណោះបង?

ខៈ បាទនិងហើយដោយសារយើងនៅតែកន្លែងហ្មោះនៅមើលគោអីនេះចឹងហើយ។

កៈ បាទ។

ខៈ បានជាយើងអតើដឹងពីការរៀបចំការម៉ាប្រាំគូរ១០គូរអីអត់ដែលឃើញទេ។

កៈ អត់ដែលឃើញនិងភ្នែកអីទេ?

ខៈ និងហើយ។

កៈ
អញ្ចឹងមួយទៀតដែលខ្ញុំចង់បកមកក្រោយវិញតិចទិដ្ឋភាពដែលគេបានសំលាប់មនុស្សនៅសម
យ័និងថាតើបងចងចាំទិដ្ឋភាពមួយណាជាគេ?

ខៈ
ចាំអាពេលវាយកទៅវាហៅទៅវាហៅទៅធម្មតាទៅតែដល់កន្លែងទៅវាអត់អោយយើងដឹងទេ។

កៈ បាទ។

ខៈ ពេលដល់កន្លែងនិងវាពត័ចាប់តែម្ដងម៉ង។

កៈ បាទ។

ខៈ ចាប់ដាក់ចងស្លាបសេកតែម្ដងទៅ។

កៈ ចងស្លាបសេក។

ខៈ
ហើយទៅដល់កន្លែងស្ងាត់បានព្រឹកឡើងអត់មាននណារដឹងទេចាប់កំអោយគេផ្ញើចឹងណា។

កៈ បាទបងបាទអញ្ចឹង។

ខៈគេយកទៅ។

កៈ
ដូចជាខ្ញុំបានតាមដានរឿងនិងខ្លះខ្ញុំបានលឺតែងតែលឺគេនិយាយថាមានអ្នកខ្លះគេមានរណ្ដៅមួ
យធំអញ្ចឹមមានគេយកបើមិនបាញ់ទេគឺវាយនិងដងកាំភ្លើង។

ខៈ និងហើយនិងដងកាំភ្លើង ឬក៏និងត្បូងចបអីនិង។

ក៖ ដងចបឬក៏ចបជីអីនិង។

ខ៖ ចបជីកអីនិង។

ក៖ បាទ។

ខ៖ គ្រាន់តែនៅក្នុងរណ្ដៅពេលខ្លះនៅកណ្ដាលបឹងអីទៅនៅតាមរាំងអីនិង។

ក៖ បាទ។

ខ៖ ប្រហែល៣រណ្ដៅ។

ក៖ បាទ។

ខ៖ សុទ្ធតែក្បាលខ្មោច។

ក៖ បាទ។

ខ៖
ហើយអាពេលយើងទៅដើលមើលគោអីយើងឃើញដូចជាអាសមយ័៧៩អាបែលដើលទៅមើលគោទៅចំអាររណ្ដៅដែលគេបានសំលាប់ចោល២ឬក៏បីរណ្ដៅ។

ក៖ បាទ។

ខ៖ ជំនាន់និងមានស្លាប់ច្រើនណាស់។

ក៖ ហើយសំរាប់បងដែលគិតថាមានមនុស្សរស់ចេញពីរណ្ដៅនិងអត់អាចមានជិវិតនៅរស់?

ខ៖ អានិងដោយសារយើងនៅតូចអត់ដឹងទេតែដោយសារបានលឺគេនិយាយ។

ក៖ ដោយសារមានគេបានរួចផុតពីរអាររណ្ដៅនិង។

ខ៖ បាទ
ថាដូចជាពេលអាព្រលឹមឡើងដូចជាបានធ្វើងាប់ចឹងទៅត្រូវដែលតែវាអត់ត្រូវកន្លែងងាប់។

ក៖បាទ។

ខ៖ ត្រូវតាមណាតាមនៃអីហើយក៏រស់មកវិញមក។

ក៖ បាទ។

ខ៖ និងហើយ។

ក៖
ហើយរូបភាពណាដែលជូរចត់ខ្លាំងនៅសម័យពុលពតនិងតើបងអាចរៀបរាប់បានទេដែលបងមានអីជូរចត់ខ្លាំងនៅសម័យនិង?

ខ៖ មានអីមានតែអារឿងស៊ីអត់ស៊ីឃ្លានអីនិងមានស៊ីក្តួចស៊ីកន្ទក់ស៊ីអីនិងស៊ីបាយជ្រូកអីនិង។

ក៖ ក្តួចនិងអីគេវិញបង?

ខ៖ ក្តួចដូចជាដំឡូងខ្យាងអីនិង។

ក៖ ដំឡូងខ្យាង។

ខ៖ អាមានរោមអីនៅខាងក្រៅ។

ក៖ មានរោមៗនៅខាងក្រៅ។

ខ៖ ប៉ុន្តែវាមានផ្លែតូចៗប៉ិននេះទេ។

ក៖ បាទ។

ខ៖ មើមវា។

ក៖ បាទ។

ខ៖ និងហើយ។

ក៖ ហើយអ៊ំបងប្អូនរបស់បងមានអ្នកស្លាប់តែម្នាក់គត់នៅក្នុងជំនាន់ពុលពតនិង?

ខ៖
នៅក្នុងជំនាន់ពុលពតបើគេយកទៅវ៉ៃចោលពេលគេយកឪអត់បានគេយកកូនទៅសំលាប់ចោលទៅ។

ក៖ បាទ។

ខ៖ ម៉ាជំនាន់ម៉ាវិកនិងគាត់និងគេចោទគាត់ថាបាត់មោងអីនិងណា។

ក៖ បាទ។

ខ៖
ម្ល៉ោះហើយដល់យប់ម៉ោង៧គាត់បានដឹងថាគាត់ដឹងតែងាប់ហើយថាគេយកទៅសំលាប់ចោលហើយថាជិតដល់គាត់លឺដូចាជាស្នូរច្រវ៉ាក់ចឹងក្រោកហើយអ៊ិចប់ហើយគាត់ក៏សូមគេនោមចឹង។

ក៖ បាទ។

ខ៖ គេចខ្លួនទៅ។

ក៖ គេចខ្លួន។

ខ៖ ៣ខែនៅដេកនៅក្នុងព្រៃ៣ខែហើយដល់ពេល។

ក៖ បាទ។

ខ៖
និងហើយយប់បានមកពេលថ្ងៃមកព្រលើមៗនៅកណ្តាលបឹងហៃលមកតោងគល់រាំងគល់អីនិង។

ក៖ បាទ។

ខ៖ យប់ឡើងចាំចូលទៅក្នុងព្រៃវិញ។

ក៖ ចឹងពួកគាត់។

ខ៖ ហើយចឹងបាន៣ខែបានវាយកបងបង្អស់យកទៅសំលាប់ចោលទៅ។

ក៖ អ៊ំគេចាប់បាននិង?

ខ៖ បាទ គេចាប់បាននៅអាកន្លែងរោងបាយនិង។

ក៖ នៅរោងបាយ។

ខ៖ វាបំរុងទៅស៊ីអី។

កៈ បាទ។

ខៈ តូចៗណាស់ខ្ញុំអត់ដឹងអីទេពីរនាក់ប្តីប្រពន្ធបងតែម្នាក់ឯងនិង។

កៈ បាទ។

ខៈ បាទនិងហើយ៣នាក់និង។

កៈ ៣នាក់និងគេយកទៅ។

ខៈ គេយកទៅវ៉ៃចោល។

កៈ គេយកទៅវ៉ៃចោល ហើយទៅបងបានទៅមើលគេវ៉ៃចោលបងអីទេ?

ខៈ យើងអត់ដឹងទេ។

កៈ ចុះឪពុកម្តាយ?

ខៈ ឪពុកអត់ដឹងទេគឺអាពត។
កៈ ឪពុកអត់ដឹងទេ។

ខៈ ហើយក៏ស្ងាត់ទៅៗគេមិនអោយដឹង។

កៈ ហើយប្រជាជននៅសម័យនិងអត់មានអារម្មក្នុងការរើលបំរាស់អីទេ?

ខៈ អត់ហ៊ានទេអត់ហ៊ានទេ។

កៈ អត់ហ៊ាន។

ខៈ
គ្រាន់តែឃើញគេញរ័គេខ្លាចគេគ្រាន់តែឃើញគេរាយការណ៏គេយកយើងទៅអានាក់ឃើញគេយកទៅវ៉ៃចោល។

កៈ គេយកទៅវ៉ៃចោល។

ខៈ បាទបើមិនចង់អត់ហ៊ានមើលទេ។

កៈ អញ្ចឹងភាគច្រើនសុទ្ធតែនាក់បាក់ស្បាត។

ខ៖ និងហើយបាក់ស្បាតខ្លាចទាំងអស់។

ក៖ ខ្លាចទាំងអស់។

ខ៖ តែគេប្រើទៅណាទៅនិងហើយ។

ក៖ ចុះម៉្តាយមានឈឺអីអត់នៅក្នុងសមយ័និង?

ខ៖ អត់អីទេ។
ក៖ អត់អីទេ។

ខ៖ អត់អីទេ ធើការតាមរបៀបធម្មតានិងស្ទូងដកធម្មតានិង។

ក៖ បាទ
អញ្ចឹងបើឈានទៅដល់នេះវិញថាតើពេលជិតបែកអាពតវិញអាពេល៧៩នេះវិញនៅពេលនិងពេលណាដែលបានឆ្នាំណាដែលបងបានលឺថាមានការមកជួយរំណ្ដោះពីរកងទព័វៀតណាមនិង?

ខ៖ ឆ្នាំ៨៣។

ក៖ ឆ្នាំ៨៣។

ខ៖ បាទ៨៣ពេលរណ្ដោះមកនៅស្រុកកំនើតវិញនៅម្តុំវត្តនិងណា។

ក៖ បាទ។

ខ៖បាទ ចាប់ពី៨៣មកបានម៉ានម៉ោលរហូតមកដល់ឆ្នាំ៨៦មក

ក៖ ៨៦។

ខ៖ ៩៦ ចាំចប់។

ក៖ បងនៅចាំទិដ្ធភាព៧៩ពេលបែកអាពតនិងទេ?

ខ៖ ចាំ។

ក៖ អាពេលគេបែកភ្លាមចឹងទៅគេបង។

ខ៖ គេជំលៀសមកអោយយើងមករកតាមស្រុកតាមភូមិវិញនិងណា។

ក៖ តាមស្រុកតាមភូមិវិញ។

ខ៖ បាទនិងហើយ។

ក៖ ហើយ។

ខ៖ ហើយបររទេះគោលរទេះក្របីអីមកឯស្រុកយើងវិញ។

ក៖ បាទ។

ខ៖ និងហើយចេញពីរស្រុកចេញពីរនេះមកនាក់មកពីរស្រុកណាមកស្រុនិងវិញមក។

ក៖
បងមានចាំពីទិដ្ឋភាពកងតព័វៀតណាមបានមកបាញ់គ្នាជាមួយកងទព័វៀតណាមបានបាញ់គ្នាទៅវិញទៅមកទេ?

ខ៖ ចាំ ពួកអានិងពួកអានេះពួកកងចក្រនិងណា។

ក៖ ពួកកងចចក្រ។

ខ៖ ជាមួយខ្មែរអីគេនោះបាន។

ក៖បាទ។

ខ៖ បានបាញ់ជាមួយកងទព័វៀតណាមសហាការគ្នា។

ក៖ បាទ ក៏បានវៃឈ្នះគេទៅ។

ខ៖ បាទ ហើយក៏ដេញខ្មែរក្រហាមចូលទៅក្នុងព្រៃអស់ទៅ។

ក៖
អ្នកដែលបានសហាការណ៏គ្នាជាមួយកងទព័វៀតណានិងដែលបានបាញ់គ្នាជាមួយខ្មែរនិងដែលបានអីសហាការណ៏ជាមួយវៀតណាមម៉ាក្រុមនិងគេហើយថាក្រុមអីកកេដែលលោកពូ?

ខ៖ គេហើយស្អីទេគេហើយថាទព័សារ៉ូ៩អីគេនិង។

កៈ ពួកគេជាកងទព័មួយផ្នែក?

ខៈជាកងទព័មួយផ្នែក។

កៈ ខ្មែរយើងដែល។

ខៈ វៀតណាមដែល។

កៈ
ដែលបានចុះចូលជាមួយវៀតណាមនិងមែនហើយដែលបានមកវ៉ៃជាមួយវៀតណាមនិងមែន?

ខៈ អើ។

កៈ ទេវ៉ៃជាខ្មែរ?

ខៈ ខ្មែរជាមួយវៀតណាមបានមកវ៉ៃជាមួយខ្មែរក្រហម។

កៈ បាទ។

ខៈ និងហើយហើយពេលបានចប់ហើយដាច់ពីនិងមកបានវាយើងខ្មែរនិងខ្មែរម្ដ៉ង។

កៈ បាទ។

ខៈ និងហើយ។

កៈ
អញ្ចឹងមកដល់ពេលរណ្ដោះហើយដល់ពេលដែលមកដល់ផ្ទះហើយជួបជុំគ្រួសារមានតែបងប្អូនសល់តែសល់តែប្រាំមួយនាក់ទេដោយសសារ។

ខៈ និងហើយ។

កៈ មានម្នាក់បានស្លាប់ហើយ។

កៈ
អញ្ចឹងដល់ពេលបែកចប់អស់ហើយសប់គ្រប់ហើយស្ថានភាពពេលនិងនៅមានភាពរឹករវរអីទេខ្លះៗមួយចំនួន?

ខៈ ដោយកន្លែង។

ក៖ ដោយកន្លែង។

ខ៖ចាប់ពីរឆ្នាំ ៨៤ដល់៨៥នៅអាជំនាន់យើងបាញ់ជាមួយខ្មែរនិងខ្មែរនិងណា។

ក៖ បាទ។

ខ៖ ជំនាន់គេដក។

ក៖ ជំនាន់គេដក។

ក៖ តែអត់សល់កងទព័វៀតណាមជាងម៉ាសែនដែលត្រូវបានពង្រាយនៅតែបន្តនៅ?

ខ៖ នៅនៅដែលនៅអាមុខនៅឯបាត់ដំបងនៅឯជំនាន់ករប្រាំនិងណា។

ក៖ បាទ។

ខ៖ ជំនាន់នោះនៅមាន។

ក៖ ដូចជាពាក្រគេនិយាយថាទៅជិះឡានមកវិញតាមទឹកវិញដែលលឺពាក្រនិងអីអត់?

ខ៖ អត់ដែលលឺទេ។

ក៖ អត់ដែលទេ។

ក៖ ចឹងហើយ
អំពើររបស់ទាហ៊ានកងទព័វៀតណាមមួយចំនួនបានប្រព្រិត្តអំពើអីខ្លះបានដឹងអត់មានចាំរឿង
ទាំងអស់និងអត់?

ខ៖ អត់ចាំទេអត់ដែលលឺទេ។

ក៖ អត់ដែលលឺទេ។

ក៖ ដូចជាការប្រមែលប្រម៉ូលទ្រព្វសម្បត្តមាសកេរ៍អាករន៍អី?

ខ៖ អត់ដែលលឺ។

ក៖ អត់ដែលលឺ។

ខ៖ អត់ដែលលឺទេ។

កៈ អើមួយទៀតកាលការក្រោយការបែកភ្លាមនិងតើបងមានបានឧកាសចូលរៀនអីអត់?

ខៈ ក៏បានចូលរៀន។

កៈ ហើយដល់ពេលដែលបងបានរៀនបងប្រកែខាងអីគេដែល?

កៈ ពេលរៀននៅសាលាបឋមអីនិង?

ខៈ បាទ ពូកែខាងប្រវត្ត។

កៈ ខាងប្រវត្តសាស្រ្ត។

ខៈ  និងហើយ។

កៈ ប្រវត្តវិទ្យា។

ខៈ ចុះផ្នែកខាងគណិតវិទ្យាអី?

ខៈ មិនសូវទេ។

កៈ មិនសូវទេ។
កៈ ខាងខ្មែរអីវិញចូលចិត្តអីអត់?

ខៈ ខ្មែរជាប់មធ្យម។

កៈ ខ្មែរជាប់មធ្យម។

កៈ ចុះផ្នែកសិប្បកម្មគំនូរអីវិញឬក៏អី?

ខៈ ចេះតិចៗ។

កៈ ចេះតិចៗ។

ខៈ ហ្នឹងហើយ។

កៈ
ហើយនៅពេលរៀននិងដែលគិតថានៅពេលអនាគតនិងធ្វើអីគេមានចង់ធ្វើអីដែលអត់បង?

ខៈ អត់អត់អត់ទាន់គិតឃើញ។

កៈ អត់ទាន់គិតឃើញ។

ខៈ នៅរៀនអោយតែបានតែចេះសិន។

កៈ បាទ អោយបានទាល់តែចេះសិន។

កៈ ហើយនៅពេលដែលលបងរៀនតើបងខ្លាហានឬក៏បងជាធម្មតា?

ខៈ ធម្មតា។

កៈ ធម្មតា។

កៈ
ហើយនៅក្នុងសមយ័ដូចជាដូចជាក្នុង៨០ស្តើងដូចជាគេមានសមយ័ករប្រាំអីគេនិងតើនៅបពេលនិងងប្រហែលជាឆ្នាំណាដែលបង។

ខៈ យើងកំពុងតែនិងដូចជាតាចាស់កំពុងតែគេដកគេចាប់ទៅហើយណា។

កៈ បាទ។

ខៈ តែយើងនៅរៀននៅឡើយចិង។

កៈ បាទ។

ខៈ ទើបតែរៀនបានថ្នាក់ទីរ៣ ទីរ៤និងណា។

កៈ បាទលោកពូ។

ខៈហើយបានដល់ឆ្នាំ៨៦និងបានមករៀននៅវត្តនេះនៃក។

កៈ បាទលោកពូ។

ខៈបានរៀនថ្នាក់ទីរប្រាំមួយឆ្នាំ១៩៨៧។

កៈ ហេតុអីម៉ោលរៀនវត្តភ្នំនៅភ្នំពេញវិញ?

ខៈ អ៊ អ៊ សាលាគេធំ។

កៈ សាលាគេធំ។

កៈ ហើយឪពុកម្ដាយក៏មកដែល?

ខៈ អត់ទេ។

កៈ អត់ទេ។

ខៈ ដើរគ្រាន់តែជិះកង់ពីរផ្ទះនិងមកប្រហែលជាម៉ាភែគីឡូដឺ។

កៈ បាទ។

ខៈ ទើបមកដល់សាលានេះនែក។

កៈ អ៊ឺសាលានៅ។

ខៈ សាលាវានៅឆ្ងាយ។

កៈ នៅសាលាវត្តភ្នំនៅកំពុងចាមនិងមែន?

ខៈ និងហើយ។

កៈ និងហើយសាលាសម្ដេចឪ។

ខៈ វាជិះទៅវាឡើងមកនែកឡើងមកខាងយើងភ្នំពេញនេះវិញ។

កៈ បាទបងបាទ។

ខៈ និងហើយ។

កៈ ខ្ញុំស្មានថាសាលាវត្តភ្នំនៅទីរក្រុងភ្នំពេញនេះទេ។

ខៈ អត់ទេ។

កៈ តែសាលានៅកំពុងចាមនោះទេ។

ខៈ នៅកំពុងចាមទេ។

កៈ
ហើយបងដែលមើលឃើញទិដ្ឋភាពដែលពេលដែលគេចាប់មនុស្សក្មេងប្រុសនៅក្នុងសមយ័ករ
ប្រាំនិងអត់ អត់ដែលឃើញទិដ្ឋភាពនិងអត់?

ខ៖ គេចាប់ ដូចជាទៅករប្រាំគេរើសទេគេអត់ចាប់ទេ។

ក៖ បាទ។

ខ៖ បាទនិងហើយ ហើយបើជំនាន់ទាហ៊ានគេចាប់។

ក៖ ជំនាន់ទាហ៊ានគេចាប់។

ខ៖ គេចាប់ទាហ៊ានចចូលកងទព័។

ក៖ ចូលកងទព័។

ក៖ អញ្ចឹងសមយ័ករប្រាំគេអត់បង្ខំទេលោកពូ?

ខ៖ គេអត់បង្ខំគេទេ  គេដើររើសដូចជាយើងស្មគ្រចិត្តទៅក៏ទៅទៅ។

ក៖ តែដូចមាននាក់ខ្លះថាដូចមានគេចាប់ដែលបង?

ខ៖ ប្រហែលជាដោយកន្លែងទៅចិង។

ក៖ ប្រហែលជាមិនមានអ្នកស្មគ្រចិត្តទៅចិងគេចាប់ម៉ង។

ខ៖ និងហើយ។

ក៖ គេចាប់យកទៅ។

ខ៖ អើនិងហើយ  នៅនេះអត់មានទេ បើនៅខាងភូមិនៅហ្នោះអត់មានទេ។

ក៖ បាទ។

ខ៖ ដូចជាថាយើងបានដូរគ្នាម៉ាវេនម្នាក់ចិងនិងណា។

ក៖ បាទ។

ខ៖ ដូរទៅរស់តែលចដូលមក។

ក៖ បាទ។

ខ៖ ថាដូចថាទៅម៉ាខែពីខែចឹងម៉ោវិញមករើសអានោះដូរវិញម្តុំង។

កៈ បាទ។

ខៈ ឆ្លាស់គ្នា។

កៈ បាទ។

ខៈ បាទ។

កៈ
ចុះបើបងគលនាថាអាសមយ័ករប្រាំបើបងគិតទៅមនុស្ស១០នាក់ដែលបានទៅហើយមានជិវិតម៉ោលវិញប្រហែលជាប៉ុន្មាននាក់មកវិញដែលបង?

ខៈ និងហើយ ម៉ោល
ដូចថាទៅ១០នាក់បើយើងទៅឃ្លានដូចថាស្អីៗឃើញផ្លែល្ហុងផ្លែអីនិងណា។

កៈ បាទ។

ខៈ យើង រុលទៅបើអត់អីអត់ជាន់មីនអត់អីទេអានឹងរស់ហើយ។

កៈ អានិងរស់។

ខៈ ហើយបើទៅជាន់មីនងាប់ហើយ យកតែឆ្អឹងមកទេ។

កៈ បាទ។

ខៈ គេហៅថាទៅជិះឡានមកវិញជិះផ្ទិល។

ខៈ ហ្នឹងហើយម៉ោលវិញជិះផ្ទិល  អានឹងវាអញ្ចឹង។

កៈ បាទហើយ  ដូចជាឆ្នាំណាបងបានជួបគ្នាជាមួយនិងភរិយារបស់បង?

ខៈ ឆ្នាំប៉ែតដូចជាឆ្នាំកៅកៅកៅបី។

ខៈ កៅបី គាត់ឈ្មោះអីគេដែល?

ខៈ ឈ្មោះគន្ធា។

កៈ គន្ធា ចុះឈ្មោះពេញរបស់គាត់?

ខ៖ និងហើយគន្ធា រស់គន្ធា។

ក៖ រស់ គន្ធា។

ខ៖ បាទ។

ក៖ គាត់ នៅពេលជួបគ្នាមានអាយុប្រហាក់ប្រហែលប៉ុន្មានដែលលោកពូល?

ខ៖ ប្រហាក់ប្រហែលជា បួនដណ្តប់ប្រាំដណ្តប់។

ក៖ បួនដណ្តប់ប្រាំដណ្តប់។

ក៖ ជួបគ្នានៅក្នុងភូមិដែលបងនៅនិងមែន?

ខ៖ មែនទេ។

ក៖ មែនទេ។

ខ៖ នៅភូមិស្តៅ។

ក៖ ភូមិស្តៅ។

ក៖ បងការនៅឆ្នាំណាដែលបង?

ខ៖ ឆ្នាំកៅបីនិង។

ក៖ ឆ្នាំកៅបី។

ក៖ ឥលូវបងមានកូនប៉ុន្មាននាក់ហើយបង?

ខ៖ កូនប្រាំមួយនាក់។

ក៖ កូនមានឈ្មោះអីគេខ្លះដែលលោកពូ?

ខ៖ ឈ្មោះពិសី នេសា កុសល និទី តី ។

ក៖ ពួកគេសុទ្ធតែបានរៀនសូត្រទាំងអស់បង?

ខ៖ បានរៀនសូត្រ។

កៈ បានទាំងអស់?

ខៈ បាទ។

កៈ
ហើយខ្ញុំប្របហែលជាអត់មានអីច្រើនសំរាប់សួរបងទៀតតែមានសំនួរបញ្ចប់មួយថាសំរាប់បងមានអាអ្វីផ្តាំផ្ញើសំរាប់មនុស្សជំនាន់ក្រោយហើយជាពិសិសចៅរបស់បងឬក៏កូនៗបងដែលនៅខាងក្រោយៗទៀតនិងមានអីផ្តាំផ្ញើសំរាប់ពួកគេដើម្បីអោយពួកគេមានជិវិតដែលប្រសើរឡើងបងមានអីផ្តាំផ្ញើដែលបង?

ខៈ
អោយក្មេងៗជំនាន់ក្រោយអោយប្រឹងរៀនសូត្រអោយចេះដឹងអោយដើរមើលតាមសង្គមគេដឹកនាំនិងណា។

កៈ បាទ។

ខៈ អោយវាចេះដឹងនិងគេនិងឯងនិងណា។

កៈ បាទ
អញ្ចឹងការសំភាសន៍របស់ខ្ញុំនមានតែប៉ុន្នឹងជាមួយនិងបងហើយសង្ឃឹមថាមនុស្សជំនាន់ក្រោយឬក៏សាច់ញាតិឬក៏ខ្មែរលិហិតរបស់បងដែលបានស្តាប់លឺវីឌីអូរនិង
និងសំលេងមួយនិងហើក៏គេបានស្គាល់បងទោះបីជាជាច្រើនឆ្នាំកន្លងទៅនៅតែបានឃើញសំលេងនៅតែបានលឺពីសំលេងរបស់បង។

ខៈ បាទ។

កៈ អញ្ចឹងអត់មានបបន្ថែបទៀតខ្ញុំសូមមានតែប៉ុនឹងបងហើយសូជំរាបលាបង។

ខៈ បាទបាទ៕